**Job Access**

Driving disability employment

# បណ្ណ័ព័ត៌មាន
# សេវានិងកម្មវិធីនានាដែលមានសំរាប់បណ្តាជនពិការ

មានសេវានិងកម្មវិធីនានាជាច្រើនសំរាប់បណ្តាជនដែលមានពិការភាព ដើម្បីជួយដល់ពួកគេក្នុងការត្រៀមខ្លួន ស្វែងរក និងរក្សាការងារ។ កម្មវិធីទាំងនោះរួមមាន ៖

## ការឧបត្ថម្ភប្រាក់បៀវត្ស

នឹងផ្តល់អោយនិយោជកនូវផលប្រយោជន៍បន្ថែមដើម្បីអោយពួកគេជួលបណ្តាជនដែលមានពិការភាពធ្វើការនៅទីកន្លែងពួកគេ ។

## ជំនួយផ្ទាល់ខ្លួនដោយផ្អែកលើការងារ

ជួយដល់ការបង់ថ្លៃចំណាយផ្សេងៗទៅលើសេវាគាំទ្រនានានៅទីកន្លែងការងារសំរាប់បណ្តាជនដែលត្រូវការជំនួយជាប្រចាំដោយសារពិការភាព ឬលក្ខណៈសុខភាពរបស់ពួកគេ។

## ប្រាក់ឧបត្ថម្ភក្នុងការធ្វើដំណើរ

អាចជួយអ្នកក្នុងការបង់ថ្លៃចំណាយលើការធ្វើដំណើរទៅនិងមកកន្លែងធ្វើការ ការសិក្សា វគ្គបណ្តុះបណ្តាល ការស្ម័គ្រចិត្តធ្វើឬស្វែងរកការងារ ប្រសិនបើអ្នកមិនអាចធ្វើដំណើរតាមយានជំនិះសាធារណៈបាន ។

## កម្មវិធីផ្តល់ជំនួយសម្រាប់ការផ្លាស់លំនៅដ្ឋានដើម្បីទទួលយកការងារមួយ

អាចជួយសងថ្លៃចំណាយក្នុងការផ្លាស់ទីលំនៅ។

## សេវាការងារផ្តល់អ្នកជួយ និងណែនាំផ្ទាល់ខ្លួន

អាចជួយអ្នកប្រសិនបើជីវិតអ្នកត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារជំងឺផ្លូវចិត្ត អ្នកទទួលបានការឧបត្ថម្ភប្រាក់ចំណូល ហើយគេតម្រូវឲ្យអ្នកស្វែងរកការងារធ្វើ។

## ជំនួយសំរាប់ពេលដែលការងារស្ថិតក្នុងស្ថានភាពមិនល្អ

មានសំរាប់អ្នកប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពដែលអាចបាត់បង់ការងារដោយសារតែពិការភាព របួស ឬលក្ខណៈសុខភាពរបស់អ្នក ។

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**

**កម្មវិធីលើកទឹកចិត្តដល់សហគ្រាសថ្មី** អាចជួយអ្នក ប្រសិនជាអ្នកចង់បើកអាជីវកម្មខ្នាតតូចថ្មីមួយ ។

**កម្មវិធីបទពិសោធន៍ការងារជាតិ** អាចជួយអ្នកប្រសិនជាអ្នកចាប់អារម្មណ៍ធ្វើការងារដើម្បីបទពិសោធន៍ ដោយទទួលប្រាក់កំរៃ ឬមិនទទួលប្រាក់កំរៃ ដើម្បីជួយដល់អ្នកទទួលបានជំនាញ និងទំនុកចិត្តក្នុងការធ្វើការងារ ។

**កម្មវិធីអភិវឌ្ឍសហគមន៍** ជួយបណ្តាប្រជាជនក្នុងការត្រៀមខ្លួនសំរាប់ការងារ និងស្វែងរកការងារនៅតំបន់ដាច់ស្រយាលក្នុងប្រទេសអូស្ត្រាលី ។

**ជំនាញនានាសម្រាប់ការសិក្សានិងការងារ** អាចជួយធ្វើអោយចំណេះរបស់អ្នកក្នុងការនិយាយ អាន សរសេរ ឬគិតលេខសាមញ្ញៗបានប្រសើរឡើង។

**សំរាប់ព័ត៌មានបន្ថែមស្តីអំពីសេវាទាំងនេះ ឬព័ត៌មានស្តីពីការងារដែលត្រូវការកែតម្រូវសម្រាប់ជនពិការ សូម មើលគេហទំព័រ** www.jobaccess.gov.au **ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់** JobAccess **តាមរយៈលេខ** 1800 464 800- **ការទាក់ទងតាមទូរសព្ទ័ដែត្រូវគេគិតថ្លៃ។**